## កម្មវិធីនិយោជកដែលទទួលស្គាល់ជាផ្លូវការរបស់ ACC

# ព័ត៌មានសម្រាប់បុគ្គលិក



ជាសះស្បើយ
ឡើងវិញ
នៅកន្លែងធ្វើការ

AFL060524 KHMER layout AEP & WA.indd 1 17/06/2024 2:05 PM

**ក្រុមហ៊ុន ANZCO Foods Limited ក្នុងភាពជាដៃគូជាមួយ ACC ក្រោមកម្មវិធីនិយោជកដែលទទួលស្គាល់ជាផ្លូវការ (AEP)។**

**នេះមានន័យថា ប្រសិនបើអ្នកមានរបួស ឬជំងឺទាក់ទងនឹងការងារ យើងធានារ៉ាប់រងលើការចំណាយទាំងអស់ រួមទាំងថ្លៃព្យាបាល និងសំណងប្រចាំសប្ដាហ៍។**

**ដើម្បីធ្វើឱ្យប្រាកដថាអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ អនុលោមតាមច្បាប់សំណងគ្រោះថ្នាក់ ឆ្នាំ2001, ច្បាប់ឯកជនភាព ឆ្នាំ2020 និងច្បាប់ឯកជនភាពស្ដីពីព័ត៌មានសុខភាព ឆ្នាំ2020 យើងបានសហការជាមួយអ្នកផ្ដល់សេវាកម្មភាគីទីបីដើម្បីចាត់ចែង និងគ្រប់គ្រងករណីទាមទារសំណងរបួសការងាររបស់យើង។**

**អ្នកផ្ដល់សេវាកម្មភាគីទីបីរបស់យើងគឺ WorkAon។**

## សេចក្ដីសម្រេចចិត្តលើការទាមទារ

WorkAon ប្រហែលជាចាំបាច់ត្រូវប្រមូលព័ត៌មានបន្ថែមអំពីការរងរបួសរបស់អ្នក មុនពេលណែនាំការសម្រេចចិត្តណាមួយទៅកាន់ ANZCO។ អ្នកនឹងត្រូវបានស្នើសុំឱ្យចុះហត្ថលេខាលើទម្រង់បែបបទយល់ព្រមមួយ ដើម្បីឱ្យគេអាចប្រមូលព័ត៌មាននេះ។

WorkAon នឹងណែនាំការសម្រេចចិត្តនានាដល់ ANZCO ដែលអនុលោមតាមច្បាប់ ACC។ ការសម្រេចចិត្តណាមួយគឺជាការទទួលខុសត្រូវរបស់ ANZCO។

## សិទ្ធិទទួល

ANZCO នឹងចាំបាច់ត្រូវអនុម័តសិទ្ធិទទួលការទាមទារសំណងរបួសការងាររបស់អ្នក។ ទាំងនេះអាចរាប់បញ្ចូលទាំងការចំណាយសម្រាប់ការព្យាបាល ដូចជាការទៅជួបវេជ្ជបណ្ឌិត ការព្យាបាលដោយចលនាកាយសម្បទា វិទ្យុសកម្ម បរិក្ខារ និងសិទ្ធិទទួលបានសំណងប្រចាំសប្ដាហ៍។

សំណងប្រចាំសប្ដាហ៍ត្រូវបានគណនាដោយ WorkAon ស្របតាមច្បាប់ ACC និងបង់ដោយក្រុមបើកបៀវត្សរ៍របស់ ANZCO ក្នុងដំណើរការបើកបៀវត្សរ៍ប្រចាំសប្ដាហ៍ធម្មតា។

អ្នកអាចធ្វើការទាមទារចំពោះការបង់សងវិញសម្រាប់ថ្នាំព្យាបាល និងថ្លៃធ្វើដំណើរទៅព្យាបាល។ សូមទៅជួបមន្ត្រីទាមទារសំណងរបួសការងាររបស់អ្នកសម្រាប់ព័ត៌មានអំពីអ្វីដែលអ្នកអាចទាមទារ និងអ្វីដែលអ្នកត្រូវផ្ដល់។

## ការគ្រប់គ្រងករណី

WorkAon នឹងបែងចែកអ្នកគ្រប់គ្រងករណីដល់អ្នក ប្រសិនបើរបួសការងាររបស់អ្នកមានរយៈពេលលើសពី7ថ្ងៃ។

អ្នកគ្រប់គ្រងករណីរបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បីគាំទ្រដល់ការស្តារនីតិសម្បទារបស់អ្នក និងការត្រឡប់ទៅធ្វើការវិញ។

ដើម្បីជួយក្នុងការកំណត់អត្តសញ្ញាណអ្វីដែលអ្នកត្រូវការដើម្បីជាសះស្បើយពីការរងរបួសរបស់អ្នក កិច្ចប្រជុំស្តារនីតិសម្បទានានានឹងត្រូវបានរៀបចំជាមួយអ្នក អ្នកគ្រប់គ្រងករណីរបស់អ្នក និងអ្នកគ្រប់គ្រងរបស់អ្នក ដើម្បីបង្កើតផែនការស្តារនីតិសម្បទាជាលក្ខណៈបុគ្គលមួយ។

អ្នកត្រូវបានលើកទឹកចិត្តជានិច្ចឱ្យនាំមនុស្សគាំទ្រទៅកាន់កិច្ចប្រជុំណាមួយ។

## ជម្លោះ / បណ្តឹងតវ៉ា

ប្រសិនបើរបួសការងាររបស់អ្នកកំពុងត្រូវបានគ្រប់គ្រងក្រោមកម្មវិធីនិយោជកដែលទទួលស្គាល់ជាផ្លូវការរបស់ ANZCO ហើយអ្នកមានបណ្តឹងតវ៉ា ឬការព្រួយបារម្ភអំពីរបួសទាក់ទងនឹងការងាររបស់អ្នក សូមទាក់ទងអ្នកគ្រប់គ្រង / នាយក ឬតំណាងនិយោជិតរបស់អ្នកជាមុនសិន។

បើមិនដូច្នេះទេ សូមទាក់ទងអ្នកគ្រប់គ្រងបណ្តឹងតវ៉ារបស់យើងតាមទូរសព្ទលេខ **027 281 4911**

អ្នកគ្រប់គ្រងករណី WorkAon អាចទាក់ទងបានតាមទូរសព្ទលេខ **0800 185 400**

WorkAON

We're with you every step of the way.

AFL060524 KHMER layout AEP & WA.indd 3 17/06/2024 2:05 PM

# តើមិនប្រាកដថាត្រូវធ្វើអ្វីខ្លះ អំពីរបួសការងាររបស់អ្នកឬ?

## បំពេញតារាងលំហូរនេះដើម្បីកំណត់ដំណើរការសមស្របនៃសកម្មភាព។




**ទំនាក់ទំនង WorkAon៖**

**0800 185 400 ឬពិភាក្សាជាមួយនិយោជក ឬតំណាងនិយោជិតរបស់អ្នក។**

AFL060524 KHMER layout AEP & WA.indd 4 17/06/2024 2:05 PM